ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី៤ ឆ្នាំ២០២០


អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ខែកុម្ភៈ ឆ្នាំ ២០២១

# មាតិកា


សេចក្តីអធិប្បាយសង្ខេប ............................................................................................១

តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ...................................................................................៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ..............................................................................................៤

២. សូចនាករតាមវិស័យ............................................................................................... ៦

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់............................................................................. ៦

២.២. អត្រាប្តូរប្រាក់.......................................................................................................៧

២.៣. ហិរញ្ញវត្ថុសាធារណៈ..................................................................................... ៨

២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន.......................................................................... ៩

២.៥. ស្ថានភាពពាណិជ្ជកម្ម.....................................................................................១៣

២.៦. ការវិនិយោគឯកជន ......................................................................................១៦

២.៧. ស្ថានភាពទេសចរណ៍.................................................................................... ១៧

២.៨. ស្ថានភាពសំណង់ .........................................................................................១៨

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ................................................១៩

# សេចក្តីអធិប្បាយសង្ខេប

សេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថាធ្លាក់ចុះក្នុងអត្រា ៣,៥%[1] ដែលបណ្តាលមកពីផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ-១៩ លើសកម្មភាពពាណិជ្ជកម្ម, វិនិយោគ និងទេសចរណ៍ ជាដើម ព្រមទាំងបង្អាក់ដល់វឌ្ឍនភាពលើការអភិវឌ្ឍសេដ្ឋកិច្ច, សង្គម និងហិរញ្ញវត្ថុ នៅក្នុងតំបន់ និងពិភពលោក ។ ទន្ទឹមនេះ, សេដ្ឋកិច្ចកម្ពុជា ក៏បាននិងកំពុងទទួលរងនូវឥទ្ធិពលអវិជ្ជមាននៃវិបត្តិជំងឺកូវីដ-១៩ មកលើវិស័យជំរុញកំណើនសេដ្ឋកិច្ចសំខាន់ៗផងដែរ ។ ជាក់ស្តែង, ចំនួនភ្ញៀវទេសចរអន្តរជាតិ, ការនាំចេញសម្លៀកបំពាក់, សកម្មភាពនៅក្នុងវិស័យសំណង់និងទុនវិនិយោគពីបរទេស បាននិងកំពុងបន្តធ្លាក់ចុះ ក្នុងត្រីមាសទី៤ ឆ្នាំ២០២០នេះ ។ ទោះបីជាយ៉ាងនេះក្តី, ការនាំចេញក្រៅពីផលិតផលកាត់ដេរ ជាពិសេស កង់, គ្រឿងបង្គុំអេឡិចត្រូនិក, ផលិតផលពីឈើ, មាស និងផលិតផលកសិកម្មផ្សេងទៀត បានបន្តរក្សាកំណើនល្អ ស្របពេលដែលរដ្ឋាភិបាលបាននិងកំពុងអនុវត្តវិធានការអន្តរាគមន៍ក្នុងការជួយរក្សាលំនឹងជីវភាពប្រជាជននិងធុរកិច្ច ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ព្រមទាំងរៀបចំផែនការស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីវិបត្តិ ។

**អតិផរណា និង អត្រាប្តូរប្រាក់** [(2)]

អតិផរណាមធ្យមប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ បានកើនឡើងក្នុងអត្រា ៣,៤% ខ្ពស់ជាងត្រីមាសទី៤ ឆ្នាំ២០១៩ ដែលមានអត្រា ២% ដែលបណ្តាលមកពីកំណើនខ្ពស់នៃក្រុមអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹងក្នុងអត្រា ៥,៥% ជាពិសេសការកើនឡើងនៃថ្លៃសាច់ជ្រូក និងត្រី ។ ទន្ទឹមនេះ, អត្រាប្តូរប្រាក់ជាមធ្យម ៤ ០៦៤ រៀល/ដុល្លារអាមេរិក បានកើនឡើង ០,២% ។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ** [(3)]

នៅត្រីមាសទី៤ ឆ្នាំ២០២០, ការប្រមូលចំណូលសរុប អនុវត្តបាន ៥,៩ ទ្រីលានរៀល (ស្មើ ២៤,៤% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ២៤,១% ក្នុងនោះ ចំណូលចរន្តសរុប ដែលប្រមូលបាន ៥,៨ ទ្រីលានរៀល បានធ្លាក់ចុះ ២៤,៤% ធៀបនឹងត្រីមាសទី៤ ឆ្នាំ ២០១៩ ។ រីឯ ចំណាយសរុបអនុវត្តបាន ៧,៧ ទ្រីលានរៀល (ស្មើនឹង ២៥,៧% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ៣០,៧% ក្នុងនោះចំណាយចរន្តសរុប ដែលអនុវត្តបាន ៤,៦ ទ្រីលានរៀល បានធ្លាក់ចុះ ៣៥,១% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ។ ការថយចុះនៃការប្រមូលចំណូល និងការអនុវត្តចំណាយ គឺបណ្តាលមកពី (១). ការថមថយខ្លាំងនៃសកម្មភាពសេដ្ឋកិច្ច, (២). ការបន្ធូរបន្ថយកាតព្វកិច្ចពន្ធ និងមិនមែនពន្ធ, និង (៣). ការរឹតត្បិត

[1] ប្រភពទិន្នន័យ÷ ការប៉ាន់ស្មានរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) គិតត្រឹមថ្ងៃទី២០ ខែមករា ឆ្នាំ២០២១

[2] ប្រភពទិន្នន័យ÷ វិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[3] ប្រភពទិន្នន័យ÷ អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ចំណាយរបស់រដ្ឋាភិបាលក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ។ ជារួម អតិរេកចរន្ត ក្នុងត្រីមាសទី៤ ឆ្នាំ២០២០នេះ មានចំនួន ១,២ ទ្រីលានរៀល ។

**ស្ថានភាពរូបិយវត្ថុ**[4]

រូបិយវត្ថុទូទៅ (M2) នៅត្រីមាសទី៤ ឆ្នាំ២០២០ មានចំនួន ១៣៦,៥ ទ្រីលានរៀល បានកើនឡើង ១៥,៣% និងទុនបម្រុងរូបិយបណ្ណបរទេសដុល បានកើនឡើងដល់ ២១,៣ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១៣,៧% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ។ ទន្ទឹមនេះ, ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ១៣១,៤ ទ្រីលានរៀល បានកើនឡើង ២២,២% ក្នុងនោះការផ្តល់ឥណទានដល់គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ និងតម្រូវការផ្ទាល់ខ្លួន បានកើនឡើងខ្ពស់គួរឱ្យកត់សម្គាល់ ។

**ពាណិជ្ជកម្មក្រៅប្រទេស**[5]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២០, ការនាំចេញទំនិញ គិតជាទឹកប្រាក់មានទំហំ ៣ ៩៧២,៤ លានដុល្លារ បានកើនឡើង ៩,៧% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ដោយសារកំណើនខ្ពស់នៃការនាំចេញកង់, គ្រឿងបង្គុំអេឡិចត្រូនិក, ផលិតផលឈើ និងមាស ។ រីឯ ការនាំចូលទំនិញ គិតជាទឹកប្រាក់សម្រេចបាន ៥ ៥០២,៦ លានដុល្លារ បានកើនឡើងក្នុងអត្រា ៤,៦ % ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ដែលបណ្តាលមកពីការកើនឡើងនៃការនាំចូលថ្នាំពេទ្យ, គ្រឿងឧបភោគបរិភោគ និងគ្រឿងអេឡិចត្រូនិក ជាដើម ។

**ទេសចរណ៍**[6]

ក្នុងត្រីមាសទី៤ ឆ្នាំ២០២០, កម្ពុជា ទទួលបានភ្ញៀវទេសចរអន្តរជាតិសរុប ៥៨ ៤៦៣ នាក់ បានធ្លាក់ចុះ ៩៦,៧% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ដោយសារផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ដែលនាំឱ្យមានការរឹតត្បិត និងការព្រួយបារម្ភក្នុងការធ្វើដំណើរឆ្លងប្រទេស ។

**ការវិនិយោគឯកជន**[7]

ស្ថានភាពវិនិយោគ បានចាប់ផ្តើមងើបឡើងបន្តិចធៀបនឹងត្រីមាសទី៣ បើទោះបីជាស្ថិតនៅក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ ។ ជាក់ស្តែង, ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ គម្រោងវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេសដែលបានអនុម័តរួច មានចំនួន ៣៣ គម្រោង បានកើនឡើង ១២ គម្រោង ធៀបនឹងត្រីមាសមុន ។ ប៉ុន្តែបើធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩, គម្រោងវិនិយោគបានធ្លាក់ចុះ ១៧ គម្រោង និងទុនវិនិយោគ បានធ្លាក់ចុះ

[4] ប្រភពទិន្នន័យ÷ ធនាគារជាតិ នៃកម្ពុជា

[5] ប្រភពទិន្នន័យ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[6] ប្រភពទិន្នន័យៈ ក្រសួងទេសចរណ៍

[7] ប្រភពទិន្នន័យៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣០,៤% ដោយសារការធ្លាក់ចុះនៃគម្រោងសាងសង់លើផ្នែកសណ្ឋាគារ, មជ្ឈមណ្ឌលពាណិជ្ជកម្ម, ផ្សារទំនើប, រោងចក្រកាត់ដេរ និងចំណីសត្វ ។

**សំណង់** [8]

ស្ថានភាពសំណង់ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ មិនទាន់មានភាពប្រសើរឡើងនោះទេ ជាក់ស្តែង, ការអនុម័តលើសំណើគម្រោងសាងសង់មានចំនួន ១ ១០២ គម្រោង បានធ្លាក់ចុះ ១១៥ គម្រោង ធៀបនឹងត្រីមាសមុន ឬបានធ្លាក់ចុះ ៣៥៣ គម្រោងធៀបនឹងត្រីមាសទី៤ ឆ្នាំ ២០១៩ ។ ការធ្លាក់ចុះនេះ ដោយសារការពន្យារ ឬផ្អាកការសាងសង់លើគម្រោងជាប្រភេទពាណិជ្ជកម្ម, ឧស្សាហកម្ម, ទេសចរណ៍ និងលំនៅឋាន ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ នេះ។

**ថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ**

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០, ទំនិញលើទីផ្សារអន្តរជាតិសំខាន់ៗ រួមមាន÷ ប្រេងឆៅ (Brent) ថ្លៃជាមធ្យម ៤៤,៥ ដុល្លារ/បារ៉ែល បានធ្លាក់ចុះក្នុងអត្រា ២៨,៩% ប៉ុន្តែកៅស៊ូ (TSR20) ថ្លៃជាមធ្យម ១ ៥៥៣,៤ ដុល្លារ/តោន, អង្ករ (បាក់៥%) ថ្លៃ ៤៩៣,៣ ដុល្លារ/តោន និងមាសថ្លៃ ២ ០៥៧,១ ដុល្លារ/អោន បានកើនឡើងក្នុងអត្រា ១២,៥%, ១៥,៩% និង ២៦,៦% រៀងគ្នា ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០១៩ ។ ចំណែកឯ សន្ទស្សន៍ថ្លៃថាមពល [9] បានធ្លាក់ចុះ ២៤,២% ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ។ ការធ្លាក់ចុះផ្នែកថាមពលនេះ ឆ្លុះបញ្ចាំងពីការថមថយក្នុងខ្សែច្រវាក់ផលិតកម្មនៃឧស្សាហកម្មធំៗ ដែលបណ្តាលមកពីផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ។ ផ្ទុយទៅវិញ សន្ទស្សន៍ថ្លៃមិនមែនថាមពល[10] និងសន្ទស្សន៍ថ្លៃលោហៈធាតុមានតម្លៃ[11] បានបន្តកើនឡើងក្នុងអត្រា ១៤,៣% និង ២៨,៣% រៀងគ្នា ធៀបនឹងត្រីមាសទី៤ ឆ្នាំ២០១៩ ។

---

[8] ប្រភពទិន្នន័យៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[9] សន្ទស្សន៍ថ្លៃថាមពល (Energy Commodity) មានដូចជាសន្ទស្សន៍ថ្លៃ÷ ធ្យូងថ្ម, ប្រេងឆៅ និងឧស្ម័ន ។

[10] សន្ទស្សន៍ថ្លៃមិនមែនថាមពល (Non-Energy Commodity មានដូចជាសន្ទស្សន៍ថ្លៃ÷ លោហៈធាតុ, កសិកម្ម និងជីគីមី ។

[11] សន្ទស្សន៍ថ្លៃលោហៈធាតុមានតម្លៃ (Precious Metals) មានដូចជាសន្ទស្សន៍ថ្លៃ÷ មាស, ប្រាក់ និងប្លាទីន ។

# តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| **សូចនាករម៉ូលដ្ឋាន** | | | | | |
| អតិផរណា (ជាមធ្យម) | % | 2.4% | 2.0% | 3.4% | |
| អត្រាប្តូរប្រាក់ (ជាមធ្យម) | រៀល/ដុល្លារ | 4,047.3 | 4,063.1 | 4,063.8 | 0,02% |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 6,151.3 | 7,695.9 | 5,815.7 | -24.4% |
| ចំណាយចរន្ត | ប៊ីលានរៀល | 5,094.3 | 7,073.6 | 4,589.8 | -35.1% |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 1,057.0 | 622.3 | 1,225.9 | 97.0% |
| **រូបិយវត្ថុ និងឥណទាន** | | | | | |
| រូបិយវត្ថុទូទៅ (M2) | ប៊ីលានរៀល | 100,240.5 | 118,436.4 | 136,542.1 | 15.3% |
| ឥណទាន* | ប៊ីលានរៀល | 106,549.4 | 136,951.4 | 158,958.1 | 16.1% |
| ឥណទេយ្យក្នុងស្រុក | ប៊ីលានរៀល | 84,341.5 | 104,054.2 | 125,360.3 | 20.5% |
| ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ | លានដុល្លារ | 14,629.1 | 18,763.3 | 21,333.9 | 13.7% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | | |
| ទំហំនាំចេញ | លានដុល្លារ | 3,112.7 | 3,619.6 | 3,972.4 | 9.7% |
| ទំហំនាំចូល | លានដុល្លារ | 4,598.9 | 5,261.0 | 5,502.6 | 4.6% |
| តុល្យភាពពាណិជ្ជកម្ម | លានដុល្លារ | (1,486) | (1,641) | (1,530) | -6.8% |
| **វិនិយោគឯកជន** | | | | | |
| គម្រោង | ចំនួន | 749 | 1,455 | 1,102 | -34.0% |
| ទុនវិនិយោគ | លានដុល្លារ | 934.7 | 4,942.9 | 1,885.3 | -58.2% |
| **ទេសចរណ៍** | | | | | |
| ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 1,825,044 | 1,796,286 | 58,463 | -96.7% |
| **សំណង់** | | | | | |
| គម្រោងអនុញ្ញាត | ចំនួន | 749 | 1,455 | 1,102 | -24.3% |
| តម្លៃសំណង់ | លានដុល្លារ | 934.7 | 4,942.9 | 1,885.3 | -61.9% |

| | ឯកតា | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (ជាមធ្យម)** | | | | | |
| អង្ករ (បាក់៥%) | ដុល្លារ/ តោន | 404.7 | 425.7 | 493.3 | 15.9% |
| ប្រេងឆៅ (Brent) | ដុល្លារ/ បារ៉ែល | 67.4 | 62.7 | 44.5 | -28.9% |
| កៅស៊ូ (TSR20) | ដុល្លារ/ តោន | 1,271.1 | 1,381.0 | 1,553.4 | 12.5% |
| មាស | ដុល្លារ/ អោន | 1,348.0 | 1,625.5 | 2,057.1 | 26.6% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា

សម្គាល់÷ * ឥណទានផ្តល់ដោយធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាស)*

| សូចនាករ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| **មុខទំនិញគ្រប់មុខ** | 175.3 | 178.9 | 185.0 | 3.4% |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 213.3 | 218.4 | 230.4 | 5.5% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 166.6 | 172.9 | 177.7 | 2.8% |
| សម្លៀកបំពាក់ និងស្បែកជើង | 149.8 | 152.5 | 158.7 | 4.0% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 126.8 | 127.9 | 130.0 | 1.6% |
| គ្រឿងសង្ហារិម សម្ភារប្រើប្រាស់ និងការថែទាំ | 150.8 | 152.9 | 153.8 | 0.6% |
| សុខាភិបាល | 136.6 | 137.2 | 137.4 | 0.1% |
| ការដឹកជញ្ជូន | 116.1 | 114.4 | 108.9 | -4.9% |
| គមនាគមន៍ | 67.5 | 67.0 | 66.5 | -0.8% |
| ការកំសាន្ត និងវប្បធម៌ | 119.1 | 119.7 | 120.8 | 1.0% |
| ការសិក្សា | 159.5 | 162.7 | 165.5 | 1.7% |
| ភោជនីយដ្ឋាន | 275.7 | 290.6 | 300.3 | 3.3% |
| ទំនិញ និងសេវាកម្មផ្សេងៗ | 144.8 | 148.9 | 156.1 | 4.8% |

ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ (ឆ្នាំគោល ២០០៦)

*រូបភាព 1 ÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.២. អត្រាប្តូរប្រាក់

*តារាង 3 ÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | 4,047 | 4,080 | 4,037 |
| 2018 | 4,012 | 4,046 | 4,073 | 4,047 |
| 2019 | 4,006 | 4,052 | 4,086 | 4,063 |
| 2020 | 4,064 | 4,087 | 40,95 | 40,64 |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

*រូបភាព 2 ÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.៣. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE)*

| ប៊ីលានរៀល | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| I. ចំណូលក្នុងប្រទេស | 6,243.1 | 7,756.3 | 5,890.0 | -24.1% |
| ១. ចំណូលចរន្ត | 6,151.3 | 7,695.9 | 5,815.7 | -24.4% |
| ក. ចំណូលសារពើពន្ធ | 4,875.5 | 6,449.1 | 5,395.3 | -16.3% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 1,275.8 | 1,246.8 | 420.4 | -66.3% |
| ២. ចំណូលមូលធន | 91.8 | 60.5 | 74.4 | 23.0% |
| II. ចំណាយសរុប | 7,518.8 | 11,109.4 | 7,704.1 | -30.7% |
| ១. ចំណាយចរន្ត | 5,094.3 | 7,073.6 | 4,589.8 | -35.1% |
| ក. ការពារ និងសន្តិសុខជាតិ | 1,082.9 | 1,321.9 | 1,009.2 | -23.7% |
| ខ. រដ្ឋបាលស៊ីវិល | 3,973.5 | 5,684.3 | 3,491.4 | -38.6% |
| គ. ចំណាយការប្រាក់ | 37.9 | 67.4 | 89.2 | 32.3% |
| ២. ចំណាយមូលធន | 2,424.5 | 4,035.8 | 3,114.3 | -22.8% |
| ឱនភាពចរន្ត (សាច់ប្រាក់) | 1,057.0 | 622.3 | 1,225.9 | 97.0% |
| ឱនភាពទូទៅ (សាច់ប្រាក់) | (1,275.7) | (3,353.0) | (1,814.0) | -45.9% |
| III. ហិរញ្ញប្បទាន | 1,275.7 | 3,353.0 | 1,814.0 | -45.9% |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 1,199.1 | 1,704.8 | 1,440.5 | -15.5% |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 66.7 | 1,648.3 | (17.5) | -101.1% |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | 9.9 | 0.0 | 391.0 | - |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 3 ÷ ស្ថានភាពហិរញ្ញវត្ថុសាធារណៈគិតជាប៊ីលានរៀល*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន

*តារាង 5 ÷ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | 48,537.9 | 59,201.7 | 66,217.7 | 11.9% |
| ឥណទេយ្យពីអនិវាសជន | 73,608.6 | 91,889.1 | 103,290.3 | 12.4% |
| ទ្រព្យអកម្មចំពោះអនិវាសជន | -25,070.7 | -32,687.4 | -37,072.6 | 13.4% |
| **ឥណទេយ្យក្នុងស្រុក** | 84,341.5 | 104,054.2 | 125,360.3 | 20.5% |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | -16,747.7 | -24,374.0 | -25,024.9 | 2.7% |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | 58.1 | 67.4 | 88.6 | 31.6% |
| ទ្រព្យអកម្មរដ្ឋាភិបាល | -16,805.8 | -24,441.3 | -25,113.5 | 2.8% |
| ឥណទេយ្យសុទ្ធចំពោះវិស័យផ្សេងៗ | 101,089.2 | 128,428.1 | 150,385.2 | 17.1% |
| ឥណទេយ្យចំពោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | 0.0 | 0.0 | 0.0 | - |
| ឥណទេយ្យចំពោះគ្រឹះស្ថានសាធារណៈមិនមែនហិរញ្ញវត្ថុ | 0.6 | 0.7 | 0.6 | -22.2% |
| ឥណទេយ្យចំពោះវិស័យឯកជន | 101,088.6 | 128,427.4 | 150,384.6 | 17.1% |
| **ទ្រព្យអកម្មជារូបិយវត្ថុទូទៅ (M2)** | 100,240.5 | 118,436.4 | 136,542.1 | 15.3% |
| *ក្នុងនោះជារូបិយបណ្ណបរទេស* | 85,869.3 | 99,650.6 | 114,564.8 | 15.0% |
| រូបិយវត្ថុ (M1) | 28,459.9 | 35,590.7 | 38,830.7 | 9.1% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | 9,013.3 | 11,906.3 | 13,474.0 | 13.2% |
| ប្រាក់បញ្ញើចរន្ត | 19,446.6 | 23,684.4 | 25,356.7 | 7.1% |
| ប្រាក់បញ្ញើផ្សេងទៀត | 71,780.1 | 82,845.5 | 97,711.4 | 17.9% |
| មូលបត្រមិនមែនភាគហ៊ុន | 0.4 | 0.2 | 0.0 | -100.0% |
| **ទុនបម្រុងជារូបិយបណ្ណបរទេសដុល (លានដុល្លារអាមេរិក)** | 14,629.1 | 18,763.3 | 21,333.9 | 13.7% |

ប្រភព: ធនាគារជាតិនៃកម្ពុជា

## រូបភាព 4 ÷ ស្ថានភាពរូបិយវត្ថុជាប្រចាំត្រីមាស




ប្រភព: ធនាគារជាតិនៃកម្ពុជា

## តារាង 6 ÷ ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជ

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 3,013.7 | 5,108.5 | 5,919.5 | 15.9% |
| ធនាគារជាតិនៃកម្ពុជា | - | - | - | - |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 2,059.2 | 3,103.7 | 3,922.2 | 26.4% |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត | 954.4 | 2,004.9 | 1,997.3 | -0.4% |
| គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ | 64,978.6 | 79,315.7 | 94,136.6 | 18.7% |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 7,523.9 | 7,906.8 | 9,858.2 | 24.7% |
| ឧស្សាហកម្មរ៉ែ | 232.6 | 253.7 | 533.1 | 110.1% |
| កម្មន្តសាល | 4,537.2 | 4,700.8 | 5,259.3 | 11.9% |
| ការផ្គត់ផ្គង់សេវាសាធារណៈ | 571.3 | 985.5 | 1,640.8 | 66.5% |
| សំណង់ | 7,787.3 | 10,196.7 | 12,783.1 | 25.4% |
| ការជួញដូរដុំ | 9,654.6 | 11,819.1 | 12,734.6 | 7.7% |
| ការជួញដូររាយ | 13,672.5 | 16,544.8 | 20,229.9 | 22.3% |

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 3,998.3 | 4,705.3 | 5,161.1 | 9.7% |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | 1,668.3 | 2,060.0 | 3,468.9 | 68.4% |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | 717.0 | 945.0 | 1,129.8 | 19.6% |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ ** | 2,666.4 | 3,837.2 | 3,566.6 | -7.1% |
| ការជួញដូរអចលទ្រព្យ | 6,210.4 | 9,005.9 | 10,924.6 | 21.3% |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | 5,738.7 | 6,355.1 | 6,846.6 | 7.7% |
| តម្រូវការផ្ទាល់ខ្លួន | 15,707.3 | 21,877.6 | 30,258.4 | 38.3% |
| ការឱ្យខ្ចីជាបុគ្គល | 6,978.9 | 9,407.9 | 12,803.2 | 36.1% |
| ការឱ្យខ្ចីតាមបណ្ណឥណទាន | 188.5 | 230.2 | 246.4 | 7.1% |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | 8,539.8 | 12,239.6 | 17,208.8 | 40.6% |
| ឥណទានផ្សេងៗ | 1,036.7 | 1,292.0 | 1,116.3 | -13.6% |
| **សរុប** | 84,736.2 | 107,594.0 | 127,539.3 | 22.2% |
| *ក្នុងនោះជារៀល* | *3,526.2* | *10,962.2* | *14,591.7** | *33.1%* |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សម្គាល់៖* ទិន្នន័យត្រីមាសទី៤ ត្រឹមខែវិច្ឆិកា ឆ្នាំ២០២០

**មិនរាប់បញ្ចូលភតិសន្យា និងការជួល អចលទ្រព្យ

*រូបភាព 5 ៖ ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជប្រចាំត្រីមាស*




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## តារាង 7 ÷ ស្ថានភាពឥណទានផ្តល់ដោយមីក្រូហិរញ្ញវត្ថុ

| (ប៊ីលានរៀល) | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| ស្ថាប័នហិរញ្ញវត្ថុ | 10.4 | 23.4 | 28.6 | 22.1% |
| កសិកម្ម | 4,593.6 | 5,692.1 | 5,298.1 | -6.9% |
| កម្មន្តសាល | 146.9 | 221.4 | 261.6 | 18.2% |
| ពាណិជ្ជកម្ម | 3,836.3 | 5,380.4 | 5,760.5 | 7.1% |
| គ្រួសារ | 8,007.4 | 10,020.2 | 8,584.7 | -14.3% |
| សេវាកម្ម | 2,390.7 | 4,236.9 | 4,387.0 | 3.5% |
| ដឹកជញ្ជូន | 1,096.3 | 1,684.5 | 1,633.3 | -3.0% |
| សំណង់ | 912.0 | 1,038.7 | 1,057.1 | 1.8% |
| ឥណទានផ្សេងៗ | 819.7 | 1,059.8 | 516.4 | -51.3% |
| **សរុប** | 21,813.2 | 29,357.5 | 27,527.3 | -6.2% |

ប្រភព: ធនាគារជាតិនៃកម្ពុជា

## *រូបភាព 6 ÷ ស្ថានភាពឥណទានតាមវិស័យផ្តល់ដោយមីក្រូហិរញ្ញវត្ថុ*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៥. ស្ថានភាពពាណិជ្ជកម្ម

*តារាង ៨÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| ថ្នាំពេទ្យ | 52.9 | 72.5 | 73.4 | 1.3% |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 135.4 | 118.3 | 147.8 | 25.0% |
| ស្ករស និងបីចេង | 10.3 | 12.3 | 17.4 | 41.1% |
| ប្រេងឆា និងអាហារផ្សេងៗ | 95.3 | 113.4 | 147.0 | 29.6% |
| បរិក្ខារសំណង់ | 294.7 | 434.2 | 400.5 | -7.7% |
| អេឡិចត្រូនិក | 113.5 | 134.4 | 216.2 | 60.8% |
| វាយនភណ្ឌ និងសម្លៀកបំពាក់ | 1,190.2 | 1,323.3 | 1,234.7 | -6.7% |
| ទោចក្រយានយន្ត | 488.4 | 568.3 | 328.6 | -42.2% |
| គ្រឿងបង្គុំរថយន្ត | 22.7 | 30.1 | 5.2 | -82.6% |
| បរិក្ខារត្រជាក់ | 11.8 | 15.6 | 15.4 | -1.7% |
| ប្រេងឥន្ធនៈ | 463.8 | 461.9 | 302.6 | -34.5% |
| ជីកសិកម្ម | 58.4 | 64.7 | 53.8 | -16.8% |
| ផ្សេងៗ | 1,576.1 | 1,884.4 | 2,059.8 | 9.3% |
| **សរុប** | 4,598.9 | 5,261.0 | 5,502.6 | 4.6% |

ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៧÷ ទំហំនាំចូលបរិក្ខារសំណង់, ប្រេងឥន្ធនៈ, ទោចក្រយានយន្ត និងវាយនភណ្ឌ (លានដុល្លារអាមេរិក)*




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង 9៖ មុខទំនិញនាំចេញ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| សម្លៀកបំពាក់ | 1,832.8 | 1,969.9 | 1,963.3 | -0.3% |
| ស្បែកជើង | 280.5 | 353.0 | 269.7 | -23.6% |
| កាបូប | 174.8 | 273.2 | 256.4 | -6.1% |
| វាយនភណ្ឌផ្សេងៗ | 43.9 | 55.1 | 59.7 | 8.3% |
| គ្រឿងបង្គុំអេឡិចត្រូនិក | 37.5 | 36.1 | 46.3 | 28.4% |
| គ្រឿងបង្គុំរថយន្ត | 43.4 | 51.0 | 42.9 | -16.0% |
| កង់ | 101.6 | 117.8 | 147.1 | 24.9% |
| ឈើមូល | 1.2 | 0.7 | 2.9 | 329.8% |
| ឈើកែច្នៃ (Veneer) | 0.2 | 0.0 | 1.1 | 14673.3% |
| ក្ដារបន្ទះ | 23.8 | 43.6 | 62.2 | 42.6% |
| ឈើកែច្នៃផ្សេងទៀត | 16.6 | 36.6 | 55.9 | 53.0% |
| អង្ករ | 146.6 | 140.2 | 142.5 | 1.7% |
| ដំឡូងមី | 17.1 | 5.5 | 7.0 | 25.6% |
| ពោតក្រហម | 0.1 | 0.1 | 0.1 | -48.0% |
| សណ្ដែក | 0.3 | 0.1 | 0.3 | 237.0% |
| ចេក | 4.0 | 17.9 | 31.9 | 78.6% |
| ស្វាយ | 1.0 | 0.7 | 0.8 | 17.2% |
| ស្វាយចន្ទី | 0.3 | 0.5 | 1.0 | 99.5% |
| កៅស៊ូ | 69.3 | 73.3 | 119.4 | 62.8% |
| ស្ករ | 10.0 | 10.7 | 22.2 | 107.3% |
| ផលិតផលជលផល | 0.2 | 0.1 | 0.1 | 10.2% |
| កសិផលផ្សេងទៀត | 1.2 | 2.6 | 2.5 | -3.4% |
| បារី | 6.0 | 5.6 | 1.5 | -74.0% |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 14.1 | 30.6 | 39.5 | 29.2% |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0.2 | 1.1 | 0.0 | -97.8% |
| មាស | 0.0 | 18.6 | 80.4 | 331.6% |
| ផ្សេងៗ | 286.2 | 375.0 | 615.5 | 64.1% |
| **សរុប** | 3,112.7 | 3,619.6 | 3,972.4 | 9.7% |

ប្រភព៖ ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 8÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*




ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 9÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព៖ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៦. ការវិនិយោគឯកជន

*តារាង 10 ÷ ស្ថិតិវិនិយោគវិស័យឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគ | ឯកតា | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| គម្រោង | ចំនួន | 54 | 50 | 33 | -34.0% |
| បង្កើតការងារ | ការងារ | 45,905 | 56,626 | 23,689 | -58.2% |
| ទុនវិនិយោគលើវិស័យ | | | | | |
| កសិកម្ម | លានដុល្លារ | 79.5 | 27.5 | 11.4 | -58.7% |
| ថាមពល | លានដុល្លារ | 58.2 | 100.4 | 1,420.8 | 1315.5% |
| ឧស្សាហកម្ម | លានដុល្លារ | 232.5 | 198.4 | 221.6 | 11.7% |
| សេវាកម្ម | លានដុល្លារ | 240.4 | 361.4 | 9.6 | -97.3% |
| ទេសចរណ៍ | លានដុល្លារ | 1,239.4 | 1,703.7 | 0.0 | -100.0% |
| **សរុប** | **លានដុល្លារ** | 1,850.0 | 2,391.5 | 1,663.4 | -30.4% |
| ទុនវិនិយោគក្នុងស្រុក | លានដុល្លារ | 718.1 | 788.4 | 1,319.9 | 67.4% |
| ទុនវិនិយោគបរទេស | លានដុល្លារ | 1,131.9 | 1,603.0 | 343.5 | -78.6% |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

*រូបភាព 10 ÷ ស្ថានភាពវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

## ២.៧. ស្ថានភាពទេសចរណ៍

*តារាង 11 ÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ*

| សូចនាករ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| **សរុប** | 1,825,044 | 1,796,286 | 58,463 | -96.7% |
| តាមផ្លូវអាកាស | 1,137,949 | 1,010,186 | 37,088 | -96.3% |
| ភ្នំពេញ | 532,014 | 503,980 | 31,190 | -93.8% |
| សៀមរាប | 507,051 | 388,964 | 33 | -100.0% |
| កងកេង | 98,884 | 117,242 | 5,865 | -95.0% |
| តាមផ្លូវគោក និងផ្លូវទឹក | 687,095 | 786,100 | 21,375 | -97.3% |
| ផ្លូវគោក | 644,921 | 731,902 | 21,375 | -97.1% |
| ផ្លូវទឹក | 42,174 | 54,198 | 0 | -100.0% |

ប្រភពៈ ក្រសួងទេសចរណ៍

*រូបភាព 11 ÷ ស្ថានភាពភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភពៈ ក្រសួងទេសចរណ៍

*រូបភាព 12 ៖ កំណើនភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

## ២.៨. ស្ថានភាពសំណង់

*តារាង 12 ៖ គម្រោងអនុញ្ញាតសាងសង់*

| គម្រោងសុំសាងសង់តាមប្រភេទសំណង់ | ឯកត្តា | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| សំណង់សាធារណៈ | គម្រោង | 8 | 15 | 17 | 13.3% |
| សំណង់លំនៅឋាន និងភូមិគ្រឹះ | គម្រោង | 605 | 1,189 | 933 | -21.5% |
| សំណង់ឧស្សាហកម្ម | គម្រោង | 14 | 68 | 56 | -17.6% |
| សំណង់ពាណិជ្ជកម្ម | គម្រោង | 92 | 138 | 75 | -45.7% |
| សំណង់ទេសចរណ៍ | គម្រោង | 29 | 40 | 20 | -50.0% |
| សំណង់វិនិយោគផ្សេងៗ | គម្រោង | 1 | 5 | 1 | -80.0% |
| **សរុប** | **គម្រោង** | 749 | 1,455 | 1,102 | -24.3% |
| **តម្លៃសាងសង់** | **លានដុល្លារ** | 934.7 | 4,942.9 | 1,885.3 | -61.9% |

ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព 13 ÷ ចំណែកនៃផ្ទៃក្រឡាសាងសង់តាមប្រភេទ (គិតជា %)*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 13 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (មធ្យមប្រចាំត្រីមាស)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| អង្ករ | ដុល្លារ/ តោន | បាងកក | 404.7 | 425.7 | 493.3 | 15.9% |
| ប្រេងឆៅ Brent | ដុល្លារ/ បារ៉ែល | ក្រុងឡុងដ៍ | 67.4 | 62.7 | 44.5 | -28.9% |
| កៅស៊ូ | ដុល្លារ/ តោន | សិង្ហបុរី | 1,271.1 | 1,381.0 | 1,553.4 | 12.5% |
| មាស | ដុល្លារ/ អោន | ក្រុងឡុងដ៍ | 1,348.0 | 1,625.5 | 2,057.1 | 26.6% |
| ពោតក្រហម | ដុល្លារ/ តោន | ស៊ីកាហ្គោ | 162.8 | 166.8 | 192.0 | 15.1% |
| សណ្តែកសៀង | ដុល្លារ/ តោន | ស៊ីកាហ្គោ | 374.4 | 377.7 | 485.8 | 28.6% |
| ប្រេងដូង | ដុល្លារ/ តោន | រ៉ុតធើដាំ | 807.4 | 857.2 | 1,313.0 | 53.2% |
| ស្ករស | ដុល្លារ/ តោន | ក្រុងឡុងដ៍ | 372.4 | 361.6 | 389.4 | 7.7% |

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង 14÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| ប្រេងឥន្ធនៈ | 64.3 | 60.3 | 43.6 | -27.7% |
| ផលិតផលកសិកម្ម | 82.8 | 85.3 | 94.3 | 10.6% |
| ម្ហូបអាហារ | 85.8 | 89.4 | 101.4 | 13.4% |
| ឈើ | 85.3 | 86.2 | 89.4 | 3.8% |
| ជីគីមី | 90.2 | 75.1 | 77.5 | 3.2% |

ប្រភពៈ គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព14÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំខែ គិតត្រឹមខែធ្នូ ឆ្នាំ២០២០, ឆ្នាំគោល ២០១០=១០០)*




ប្រភពៈ គេហទំព័រធនាគារពិភពលោក

*តារាង 15 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (ចុងត្រីមាស)*

| រូបិយប័ណ្ណ | ត្រីមាសទី៤ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២០ |
| ជប៉ុន (Yen) | 110.2 | 109.1 | 103.2 | -5.3% |
| ហុងកុង (Dollar) | 7.8 | 7.8 | 7.8 | -0.4% |
| សិង្ហបុរី (Dollar) | 1.4 | 1.3 | 1.3 | -1.8% |
| ម៉ាឡេស៊ី (Ringgit) | 4.2 | 4.1 | 4.0 | -1.7% |
| ហ្វីលីពីន (Peso) | 52.6 | 50.8 | 48.0 | -5.4% |
| ថៃ (Baht) | 32.4 | 30.0 | 29.9 | -0.1% |
| ឥណ្ឌូនេស៊ី (Rupiah) | 14,555.8 | 13,915.3 | 14,046.3 | 0.9% |
| កូរ៉េខាងត្បូង (Won) | 1,115.6 | 1,156.4 | 1,086.9 | -6.0% |
| តៃវ៉ាន់ (Dollar) | 30.6 | 30.0 | 28.1 | -6.5% |
| ចិន (Yuan Renminbi) | 6.9 | 7.0 | 6.5 | -6.6% |
| ឡាវ (Kip) | 8,532.5 | 8,690.1 | 9,121.4 | 5.0% |
| វៀតណាម (Dong) | 23,187.0 | 23,129.1 | 23,060.1 | -0.3% |
| ឥណ្ឌា (Rupee) | 69.5 | 71.3 | 73.2 | 2.6% |
| រុស្ស៊ី (Ruble) | 69.4 | 61.9 | 74.2 | 19.8% |
| អូស្ត្រាលី (Dollar) | 1.4 | 1.4 | 1.3 | -8.7% |
| អង់គ្លេស (Pound) | 0.8 | 0.8 | 0.7 | -3.4% |
| អឺរ៉ុប (Euro) | 0.9 | 0.9 | 0.8 | -8.8% |

ប្រភព: *គេហទំព័រអូអែនដេ*(www.oanda.com)